ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ២២៨០ អពដ


# លិខិតចូលរួមរំលែកមរណទុក្ខ

**សូមគោរពជូន**

**ឧបាសិកា លីន ដា ជាភរិយា និងលោក លោកស្រីជាកូន កូនប្រសា**

**សពឧបាសក ឯកឧត្តម កែវ សាវុធ**

ខ្ញុំបាទ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃអគ្គនាយកដ្ឋានពន្ធដារ មានសេចក្តីក្ដុកក្ដួលរន្ធត់ចិត្តឥតឧបមាដោយបានទទួលដំណឹងថា **ឯកឧត្តម កែវ សាវុធ** អតីតអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ និងជាអនុប្រធានសមាគមបុគ្គលិកពន្ធដារកម្ពុជា បានទទួលមរណភាពនៅថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៤ ត្រូវនឹងថ្ងៃពុធ ១១ កើត ខែស្រាពណ៍ ឆ្នាំមមី ឆស័ក ព.ស ២៥៥៨ វេលាម៉ោង ១០ និង៤៥នាទីព្រឹក ក្នុងជន្មាយុ ៦៧ ឆ្នាំ ដោយរោគាពាធ។

ក្នុងឱកាសប្រកបដោយក្តីទុក្ខក្រៀមក្រំជាអនេកប្បការ រំជួលចិត្តរកទីបំផុតគ្មាននេះផងដែរ យើងខ្ញុំទាំងអស់គ្នាសុំអនុញ្ញាតសម្ដែងនូវសមានទុក្ខដ៏មហាធំធេង ព្រមទាំងមានសេចក្ដីសង្វេគយ៉ាងខ្លាំងជាទីបំផុត និងពោរពេញដោយសេចក្ដីសោកស្ដាយស្រណោះអាឡោះអាល័យក្រៃពន់ពេកចំពោះ **ឯកឧត្តម កែវ សាវុធ** ដែលលោកបានដាក់អាយុសង្ខារលាចាកលោក និងចាកពីយើងខ្ញុំទាំងអស់គ្នា។

ការបាត់បង់ **ឯកឧត្តម កែវ សាវុធ** នាឱកាសនេះ គឺជាការបាត់បងដ៏ធំធេងដែលកន្លងមកជានិច្ចកាល **ឯកឧត្តម កែវ សាវុធ** បានលះបង់កម្លាំងកាយចិត្តដ៏មោះមុតបំផុត បូជាចំពោះសង្គមជាតិ និងបានរួមចំណែកជួយកសាងសមិទ្ធផលនានា ប្រកបដោយភាពដ៏ឧត្តុង្គឧត្តម នៅអគ្គនាយកដ្ឋានពន្ធដារ ក៏ដូចជានៅទីកន្លែងដទៃទៀតដែរ។

ជាថ្មីម្តងទៀត ខ្ញុំបាទ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៃអគ្គនាយកដ្ឋានពន្ធដារ សូមលំឱនកាយវាចាចិត្តឧទ្ទិស បួងសួងដល់ដួងវិញ្ញាណក្ខន្ធ **ឯកឧត្តម កែវ សាវុធ** សូម**ឯកឧត្តម**បានចាប់បដិសន្ធិក្នុងទីសុគតិភពគ្រប់ៗជាតិកុំបីឃ្លៀងឃ្លាតឡើយ។

សូមឧបាសិកា **លីន ដា** ជាភរិយា និងលោក លោកស្រីជាកូន កូនប្រសា សពឧបាសក **ឯកឧត្តម កែវ សាវុធ** មេត្តាទទួលនូវគារវភក្តិភាពដ៏ស្មោះស្ម័គ្រ និងកតញ្ញូតាធម៌ដ៏ខ្ពង់ខ្ពស់បំផុត ពីខ្ញុំ

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែសីហា ឆ្នាំ២០១៤

**ប្រតិភូរាជរដ្ឋាភិបាល**

**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**